**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**
លេខ: ១៤៨៤៧ ប្រក

# ប្រកាស

## ស្តីពី

## ការតែងតាំងមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃ ដើម្បីគាំទ្រការអនុវត្តចំណាយប្រតិបត្តិការ អាទិភាព នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ សម្រាប់អនុកម្មវិធីទី២ នៃផែនការអនុវត្តរយៈពេល០៣ឆ្នាំ (ផអ៣) ពីឆ្នាំ២០១១-២០១៣

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ៦៦ អនក្រ.បក ចុះថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១០ ស្តីពីការបង្កើត និងដាក់ឱ្យអនុវត្តចំណាយប្រតិបត្តិការអាទិភាពក្នុងក្របខ័ណ្ឌសហប្រតិបត្តិការអភិវឌ្ឍ
- យោងឯកសារផែនការអនុវត្តរយៈពេល០៣ឆ្នាំ ២០១១-២០១៣ នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- យោងលិខិតលេខ ៨៨១ សជណ ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ ១ :** ត្រូវបានតែងតាំងមន្ត្រីរាជការស៊ីវិលក្រសួងមហាផ្ទៃចំនួន **២៤រូប** ដើម្បីគាំទ្រការអនុវត្តចំណាយប្រតិបត្តិការអាទិភាព នៃកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិសម្រាប់អនុកម្មវិធីទី២ នៃផែនការអនុវត្តរយៈពេល ០៣ឆ្នាំ ( ផអ៣ ) ពីឆ្នាំ២០១១-២០១៣ ដូចមានរាយនាមខាងក្រោម :

១. ឯកឧត្តម **លេខ ទី** នាយករងកម្មវិធី និងជាប្រធានក្រុមការងារគ្រប់គ្រងអនុកម្មវិធីទី២

២. ឯកឧត្តម **អែម ប៊ុនថុល** ប្រធានគ្រប់គ្រងគម្រោង

៣. លោក **ឃិន ម៉ាលីណា** អនុប្រធានគ្រប់គ្រងគម្រោង ។

**ក-ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុ**

៤. លោក **អ៊ិង ចន្ធី** ប្រធានផ្នែក

៥. លោក **គីមសួគី តេតង់** អនុប្រធានផ្នែក

៦. កញ្ញា **សុខ វិសុទ្ធា** មន្ត្រីបច្ចេកទេសរដ្ឋបាល

៧. កញ្ញា **ហេង សុវិចា** មន្ត្រីបច្ចេកទេសហិរញ្ញវត្ថុ ។

**ខ-ផ្នែកអភិវឌ្ឍសមត្ថភាព**

៨. លោក **ឈិន សេងខូន** ប្រធានផ្នែក

៩. លោក **អ៊ុំ សុភ័ណ** អនុប្រធានផ្នែក

១០. លោក **សុត កុសល្យ** មន្ត្រីបច្ចេកទេសអភិវឌ្ឍសមត្ថភាព

១១. លោក **លឿន វណ្ណៈ** មន្ត្រីបច្ចេកទេសអភិវឌ្ឍសមត្ថភាព

១២. លោក **ទិត្យ ពិសិដ្ឋ** មន្ត្រីបច្ចេកទេសអភិវឌ្ឍសមត្ថភាព ។

**គ-ផ្នែកតាមដាន វាយតម្លៃ ព័ត៌មាន និងក្របខ័ណ្ឌច្បាប់**

១៣. លោក **ប្រាក់ សំអឿន** ប្រធានផ្នែក

១៤. លោក **ស្រេង សុភាព** អនុប្រធានផ្នែក

១៥. លោក **អ៊ុំ ចំរើន** មន្ត្រីបច្ចេកទេសតាមដាន វាយតម្លៃ ព័ត៌មាន និងក្របខ័ណ្ឌច្បាប់

១៦. លោក **យឹម សំអុល** មន្ត្រីបច្ចេកទេស តាមដាន វាយតម្លៃ ព័ត៌មាន និងក្របខ័ណ្ឌច្បាប់

១៧. លោក **ឆាង ច័យ** មន្ត្រីបច្ចេកទេស តាមដាន វាយតម្លៃ ព័ត៌មាន និងក្របខ័ណ្ឌច្បាប់

១៨. លោក **ថន ពិសិដ្ឋ** មន្ត្រីបច្ចេកទេស តាមដាន វាយតម្លៃ ព័ត៌មាន និងក្របខ័ណ្ឌច្បាប់ ។

**ឃ-ផ្នែកគាំទ្រគម្រោងថ្នាក់ក្រោមជាតិ**

១៩. លោក **សី ថរិន** ប្រធានផ្នែក

២០. លោក **សួន តារា** អនុប្រធានផ្នែក

២១. លោក **សេង សីលា** អនុប្រធានផ្នែក

២២. លោក **ខា ប៊ុនហេង** មន្ត្រីបច្ចេកទេសគាំទ្រគម្រោងថ្នាក់ក្រោមជាតិ

២៣. លោក **ជេដ្ឋ គីមជុង** មន្ត្រីបច្ចេកទេសគាំទ្រគម្រោងថ្នាក់ក្រោមជាតិ

២៤. លោក **ញ៉ាន តង** មន្ត្រីបច្ចេកទេសគាំទ្រគម្រោងថ្នាក់ក្រោមជាតិ ។

**ប្រការ ២ :** មន្ត្រីរាជការ ដូចមានរាយនាមក្នុងប្រការ១ខាងលើ ត្រូវទទួលបានប្រាក់ឧបត្ថម្ភចំណាយប្រតិបត្តិការអាទិភាព ប្រចាំខែ **ចាប់ពីថ្ងៃទី០១ ខែមេសា ឆ្នាំ២០១១** តទៅ ។

**ប្រការ ៣ :** បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៤ :** អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលមូលដ្ឋាន អគ្គនាយកនៃអគ្គនាយកដ្ឋានភស្តុភារ និងហិរញ្ញវត្ថុ ក្រុមប្រឹក្សា និងគណៈអភិបាលរាជធានី ខេត្ត ប្រធាននាយកដ្ឋានបុគ្គលិក និងបណ្ដុះបណ្ដាលវិជ្ជាជីវៈនៃក្រសួងមហាផ្ទៃ និងសាមីខ្លួនដូចមានចែងក្នុងប្រការ១ខាងលើ ត្រូវអនុវត្តប្រកាសនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ សីហា ឆ្នាំ ២០១១*

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**

**ស ខេង**

**កន្លែងទទួល :**

- *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល*
- *លេខាធិការដ្ឋាន គ.ជ.អ.ប*

"*ដើម្បីជូនជ្រាប*"

- *ដូចប្រការ ៤*
- *ឯកសារ - កាលប្បវត្តិ*